# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៨. សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីពិភាក្សាលើឯកសារទស្សនទានកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីពិភាក្សាការងារជាមួយភាគីថៃ លើឯកសារទស្សនទានពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍតាមបណ្តោយព្រំដែន មានសមាសភាព ដូចខាងក្រោមនេះ :

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | ឡុង | វិសាលោ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- ឯកឧត្តម | វ៉ា | គឹមហុង | ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន | អនុប្រធាន |
| ៣- ឯកឧត្តម | ទីយ៉េ | ចឿន | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| ៤- ឯកឧត្តម | សក់ | សេដ្ឋា | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- ឯកឧត្តម | ខៀវ | មុត | អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន | សមាជិក |
| ៦- ឯកឧត្តម | ម៉ៅ | ថូរ៉ា | អគ្គនាយកបច្ចេកទេស ក្រសួងពាណិជ្ជកម្ម | សមាជិក |

៧- ឯកឧត្តម **ស៊ូ ម៉ារ៉ា** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ សមាជិក

៨- ឧត្តមសេនីយ៍ឯក **ឈុំ សុខវាត** នាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

៩- ឧត្តមសេនីយ៍ទោ **ចាន់ អឿន** ប្រធាននាយកដ្ឋាននគរបាលព្រំដែន ក្រសួងមហាផ្ទៃ សមាជិក

១០- ឧត្តមសេនីយ៍ទោ **មៀច សុផានណា** ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

១១- លោក **ហែម សាវង** ប្រធាននាយកដ្ឋានអាស៊ី ១ ក្រសួងការបរទេស សមាជិក

១២- បណ្ឌិត **គុណ ញឹម** នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

១៣- បណ្ឌិត **ជា វ៉ាន់ដេត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៤- លោក **លី ស៊ីវណ្ណា** អនុប្រធាននាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ២ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវបង្កើតឡើងដើម្បីរៀបចំឯកសារទស្សនទាន និងពិភាក្សាការងារជាមួយភាគីថៃ ជុំវិញបញ្ហាពាក់ព័ន្ធនានា នៃទំនាក់ទំនងឆ្លងដែន សន្តិសុខ ការអភិវឌ្ឍតំបន់ព្រំដែនជាដើម ។

**ប្រការ៣ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៤ :** គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយអាចប្រើប្រាស់ត្រារបស់ក្រសួងនេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៥ :** គណៈកម្មការអន្តរក្រសួងនេះ នឹងអស់សុពលភាព នៅពេលបញ្ចប់បេសកកម្មរបស់ខ្លួន ដូចមានចែងក្នុងប្រការ ២។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ